GOLDEN TREE



# របាយការណ៍ ប្រចាំត្រីមាសទី២

# ២០២៣

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

(ពាន់រៀល)

| ស្ថានភាពហិរញ្ញវត្ថុ | បានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២៣ | រងសវនកម្ម<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | រងសវនកម្ម<br>ថ្ងៃទី៣១ ខែធ្នូឆ្នាំ ២០២១ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ១៣៩.៧៧០.៤២៩ | ១៤៤.៧៤៥.៥៨៤ | ១០១.៨០៤.៣១៣ |
| បំណុលសរុប | ១១៧.២៩៨.៨១៥ | ១២១.១៧៣.៧៨២ | ៧៨.៧០៤.៥២៦ |
| មូលធនសរុប | ២២.៤៧១.៦១៤ | ២៣.៥៧១.៨០២ | ២៣.០៩៩.៧៨៧ |
| **លទ្ធផលហិរញ្ញវត្ថុ** | **បានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២៣** | **មិនបានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២២** | **មិនបានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២១** |
| ចំណូលសរុប | ២.៦១៩.៦៤១ | ៣.១១៤.២៣៥ | ៣.៣៥៥.៧០៩ |
| ចំណេញ/(ខាត)មុនពេលបង់ពន្ធ | (៥២៨.៥១៤) | ៣៨០.៩៤៩ | ៧៣៩.៧៤១ |
| ចំណេញ/(ខាត)ក្រោយពេលបង់ពន្ធ | (៥៥២.៦៣២) | ៣៧០.៣១០ | ៦៧៦.១៨៧ |
| **អនុបាតហិរញ្ញវត្ថុ** | **បានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២៣** | **រងសវនកម្ម<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | **រងសវនកម្ម<br>ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១** |
| អនុបាតសាធនភាព | ១៦,០៨% | ១៦,២៨% | ២២,៦៩% |
| អនុបាតចរន្ត | ០,៣៩ | ០,២៥ | ០,៣០ |
| អនុបាតចរន្តលឿន | ០,៣៩ | ០,២៥ | ០,៣០ |
| **អនុបាតហិរញ្ញវត្ថុ** | **បានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២៣** | **មិនបានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២២** | **មិនបានត្រួតពិនិត្យ<br>ត្រីមាសទី២ ឆ្នាំ ២០២១** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | -០,៤០% | ០,២៦% | ០,៦៦% |
| អនុបាតចំណេញធៀបនឹងមូលធន | -២,៤៦% | ១,៥៧% | ២,៩៣% |
| គម្លាតចំណេញដុល | ៦៥,៨៥% | ៧៣,០១% | ៧៨,៣០% |
| គម្លាតចំណេញ | -២១,១៩% | ១១,៩០% | ២០,១៦% |
| ចំណេញមុនការប្រាក់ពន្ធនិងរលោះ | ៦៨,៥៦% | ៧៥,៩៨% | ៨១,៨៥% |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## ទ្រព្យសកម្មសរុប

-៣,៤%

ធៀបនឹងឆ្នាំ ២០២២

ត្រីមាសទី២ ឆ្នាំ២០២៣: ១៣៩.៧៧០.៤២៩

ឆ្នាំ២០២២: ១៤៤.៧៤៥.៥៨៤

ឆ្នាំ២០២១: ១០១.៨០៤.៣១៣

## បំណុលសរុប

-៣,២%

ធៀបនឹងឆ្នាំ ២០២២

ត្រីមាសទី២ ឆ្នាំ២០២៣: ១១៧.២៩៨.៨១៥

ឆ្នាំ២០២២: ១២១.១៧៣.៧៨២

ឆ្នាំ២០២១: ៧៨.៧០៤.៥២៦

## មូលធនសរុប

-៤.៧%

ធៀបនឹងឆ្នាំ ២០២២

ត្រីមាសទី២ ឆ្នាំ២០២៣: ២២.៤៧១.៦១៤

ឆ្នាំ២០២២: ២៣.៥៧១.៨០២

ឆ្នាំ២០២១: ២៣.០៩៩.៧៨៧

## អត្រាផ្ទួល

៧៧%

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

ត្រីមាសទី២ ឆ្នាំ២០២៣: ៧៧%

ឆ្នាំ២០២២: ៨៣%

ឆ្នាំ២០២១: ៨៤%

## ចំណូលសរុប

-១៥,៩%

ធៀបនឹងត្រីមាសទី២ ឆ្នាំ ២០២២

ត្រីមាសទី២ ឆ្នាំ២០២៣: ២.៦១៩.៦៤១

ត្រីមាសទី២ ឆ្នាំ២០២២: ៣.១១៤.២៣៥

ត្រីមាសទី២ ឆ្នាំ២០២១: ៣.៣៥៥.៧០៩

## ចំណេញមុនការប្រាក់ពន្ធ និងរលោះ

-២៤,៤%

ធៀបនឹងត្រីមាសទី២ ឆ្នាំ ២០២២

៦៨,៦%

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣

ត្រីមាសទី២ ឆ្នាំ២០២៣: ១.៧៨៨.៥៤០

ត្រីមាសទី២ ឆ្នាំ២០២២: ២.៣៦៥.២៨៩

ត្រីមាសទី២ ឆ្នាំ២០២១: ២.៧៤៥.៦៨៨

# ក្រុមប្រឹក្សាភិបាល



លោក ហុង អ៊ុយ
ប្រធានក្រុមប្រឹក្សាភិបាល



លោក សុខ ពិសិដ្ឋ
អភិបាលមិនប្រតិបត្តិ



លោក អៀង សែ
អភិបាលមិនប្រតិបត្តិ



លោក លី លាង
អភិបាលឯករាជ្យ



លោក គឹង កបកល្យាន
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

**ជម្រាបសួរ មិត្តភក្តិ ដៃគូរ និងវិនិយោគិន របស់ ក្រុមហ៊ុន ហ្គោលដេន ទ្រី ជាគោរព!**

តាំងនាមឲ្យ ក្រុមហ៊ុន ហ្គោលដេន ទ្រី និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទពិតជាមាន សេចក្តីសោមនស្សរីករាយក្នុងការផ្តល់ជូននូវរបាយការណ៍ក្នុងគ្រាត្រីមាសទី២ ក្នុងឆ្នាំ២០២៣ ដែលគិតចាប់ពី ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០២៣ ដល់ថ្ងៃ ទី ៣០ ខែមិថុនា ឆ្នាំ២០២៣។

## ទិដ្ឋភាពទូទៅនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

ចំពោះស្ថានភាពម៉ាក្រូសេដ្ឋកិច្ច សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាមានការកើនឡើងវិញក្នុងឆ្នាំនេះគួរឲ្យកត់សម្គាល់។ យោងតាមធនាគារជាតិនៃកម្ពុជា (NBC) សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាត្រូវបានរំពឹងថានឹងមានការកើនឡើង ៥,៥% នៅក្នុងឆ្នាំ ២០២៣ ជាមួយអតិផរណាដែលត្រូវបានគេរំពឹងថាមានក្នុងអត្រា២%ក្នុងមួយឆ្នាំ។ គេរំពឹងថាសេដ្ឋកិច្ច នឹងមានការកើនឡើងបន្ថែមទៀតដល់ ៦,២% ក្នុងឆ្នាំ ២០២៤។ ដោយសារការបើកដំណើរការឡើងវិញរបស់ប្រទេសចិនបានធ្វើឲ្យ វិស័យទេសចរណ៍ និងសេវាកម្មក្នុងប្រទេសកម្ពុជាមានការងើបឡើងវិញ។ ក្នុងរយៈពេលប្រាំខែដំបូងក្នុងឆ្នាំ ២០២៣ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិជាង ២.១៦ លាននាក់ កើនឡើង ៥៣០ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ។

ការវិនិយោគផ្ទាល់ពីបរទេស (FDI) នៅកម្ពុជាកើនដល់ ៤៥ ពាន់លានដុល្លារគិតត្រឹមត្រីមាសទី ១ ឆ្នាំ ២០២៣ បានកើនឡើង ៩% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្នុងចំណោម ការវិនិយោគផ្ទាល់ពីបរទេស ប្រទេសចិនឈរលើគេក្នុងបញ្ជីដែលការវិនិយោគមានប្រមាណ ២០,៥៩ពាន់លានដុល្លារ។ វិស័យអចលនទ្រព្យ និងសំណង់បានទាក់ទាញប្រមាណ ៦ ពាន់លានដុល្លារ។

បំណុលសាធារណៈកម្ពុជានៅតែត្រូវបានវាយតម្លៃថាស្ថិតក្នុងភាពអាចគ្រប់គ្រងបានដែលបំណុលនោះគិតត្រឹមឆ្នាំ២០២២ មានប្រមាណ ៣៦,៥% បើធៀបនឹងផលិតផលក្នុងស្រុកសរុប ។ ហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាប ដោយសារបំណុលកម្ពុជាស្ថិតក្នុងលក្ខខណ្ឌសម្បទាន និងអាចគ្រប់គ្រងបាន ។ អត្រាការប្រាក់ជាមធ្យមមាន ១,០៨% ក្នុងឆ្នាំ ២០២២។ ឥណប្រតិទានមធ្យម គឺ ២៦.៧ ឆ្នាំ ក្នុងឆ្នាំ ២០២២។

ក្រុមហ៊ុន ហ្គោលដេន ទ្រី រំពឹងថាកំណើនដ៏រឹងមាំនេះ នឹង ផ្តល់ នូវទំនុកចិត្ត និងទាក់ទាញដល់ វិនិយោគិនបរទេសនានា ឲ្យមកវិនិយោគនៅក្នុងប្រទេសកម្ពុជាឲ្យបានច្រើននាពេលដ៏ខ្លីខាងមុខនេះ។ ម្យ៉ាងវិញទៀត ក្រុមហ៊ុនរំពឹងថា តម្រូវការសម្រាប់ជួលអាគារ នឹងមានការកើនឡើង ហើយវិស័យអចលនទ្រព្យ នឹងមានការរីកលោតលាស់ឡើងវិញ ។

## ទិដ្ឋភាពទូទៅនៃវិស័យអចលនទ្រព្យ

វិស័យជួលការិយាល័យមានការអភិវឌ្ឍន៍ជាវិជ្ជមានគួរឲ្យកត់សម្គាល់។ គិតត្រឹមត្រីមាសទី២ឆ្នាំ២០២៣ អាត្រាជួលការិយាល័យឯកកម្មសិទ្ធិឈានដល់ ៧៣% បើធៀបទៅនឹងឆ្នាំ ២០២២ ដែលមានត្រឹមតែ ៦៩,៤%។ ការផ្គត់ផ្គង់ការិយាល័យថ្មី ត្រូវបានគេរំពឹងថានឹងមានកើនឡើងសម្រាប់ប៉ុន្មានឆ្នាំខាងមុខ។ យ៉ាងណាវិញអគារពហុកម្មសិទ្ធិ នឹងមានច្រើនជាង ៥០% នៃការផ្គត់ផ្គង់សរុបនាពេលអនាគត។ ការផ្គត់ផ្គង់សរុបចំនួន៤០% ត្រូវបានរំពឹងថា ជាអគារពហុកម្មសិទ្ធិនៅចុងឆ្នាំ២០២៣នេះ ។

អាជាតមិនសេវាកម្មបាន ងើបឡើងវិញជាវិជ្ជមាននៅឆ្នាំ ២០២៣។ ការត្រលប់មកវិញរបស់ អ្នកជួលដែលបានចាកចេញក្នុងអំឡុងពេលជំងឺរាតត្បាត ត្រូវបានរកឃើញថាជាកត្តាសំខាន់មួយដើម្បីជំរុញការស្ទុះងើបឡើងវិញនៃអត្រាជួល។ ប្រទេសកម្ពុជារំពឹងថានឹងមានភ្ញៀវទេសចរចំនួន ៤,៥ លាននាក់នឹងមកទស្សនានៅដំណាច់ឆ្នាំ ២០២៣។ ដោយហេតុថាចំនួនប្រតិបត្តិករអាជាតមិនសេវាកម្មពិភពលោកធំៗនៅក្នុងប្រទេសនៅមានកម្រិតនៅឡើយនោះ ទីផ្សារនេះត្រូវបានគេរំពឹងថានឹងបន្តមានតម្រូវការច្រើន។

លើសពីនេះការទទួលយកស្តង់ដារ បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) មានការកើនឡើង។ ហេតុដូចនេះអគារពាណិជ្ជកម្មក៏ត្រូវតែទទួលយកស្តង់ដារនេះផងដែរ ។ យោងតាមរបាយការណ៍ CBRE និរន្តរភាពបរិស្ថានឥឡូវនេះត្រូវបានគេចាត់ទុកថាជាគោលដៅសំខាន់សម្រាប់អ្នកវិនិយោគស្ថាប័នភាគច្រើន។ ជាលទ្ធផលសម្ពាធនឹងកើតមានលើម្ចាស់អគារ និងអតិថិជនរបស់ខ្លួន ដើម្បីធ្វើយ៉ាងណាឲ្យសម្រេច បាននូវគោលដៅរបស់ ESG ។ អគារ វីត្រាស់ ថៅវើ បានក្លាយទៅជាអគារបៃតងក្នុង ឆ្នាំ ២០២២ ដោយជោគជ័យ ហើយក្រុមហ៊ុន ក៏គ្រោងនឹងប្រែក្លាយ អមរ៉ា រេស៊ីដេន ទៅជាអគារបៃតងដែលរំពឹងថានឹងបញ្ចប់នៅឆ្នាំ ២០២៤។

## ព្រឹត្តិការណ៍ និងបច្ចុប្បន្នភាពសំខាន់ៗរបស់ក្រុមហ៊ុន ហ្គោលដេន ទ្រី

ក្នុងអំឡុងត្រីមាសទី២ ឆ្នាំ២០២៣ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពរឹងមាំ។ អាត្រាជួលរបស់ អគារ វីត្រាស់ ថៅវើ មានរហូតដល់ ៧៧% បើប្រៀបធៀបទៅនឹងអាត្រាជួល ជាមធ្យមដែលមានត្រឹមតែ ៦៥% ប៉ុណ្ណោះ។

សម្រាប់ឆ្នាំ ២០២៣ ក្រុមហ៊ុន ហ្គោលដេន ទ្រី នឹងបន្តខិតខំប្រឹងប្រែងសម្រេចផែនការអត្រាជួលរបស់អគារឲ្យបានខ្ពស់និងបន្ត ថែទាំអគារឲ្យបានបិតថេរនិងប្រណិតភាព ដោយបន្តវិនិយោគបន្ថែមលើគ្រឿងបរិក្ខារ បច្ចេកវិទ្យាទំនើប និងបង្កើតទីកន្លែងផ្តល់សេវាកម្មបន្ថែមផ្សេងៗ។ ជាក់ស្តែង ក្រុមហ៊ុន គ្រោងនឹងសម្ពោធសាកល្បងដំណើរការហាងកាហ្វេអន្តរជាតិមួយនៅ សាលទទួលភ្ញៀវក្នុងខែសីហា ឆ្នាំ២០២៣ ដើម្បីផ្តល់ឱ្យអតិថិជនរបស់យើងទទួលបាននូវ កាហ្វេដែលមាន រសជាតិដ៏ឈ្ងុយឆ្ងាញ់ បរិយាកាសថ្មីភ្លែក និង សេវាកម្មដ៏ល្អ ដើម្បីជួប ធ្វើការ និងពិភាក្សាការងារ ។

ការសាងសង់ អមរ៉ា រេស៊ីដេន បានដំណើរការមកដល់ដំណាក់កាលចុងក្រោយហើយ។ ក្នុងអំឡុងត្រីមាសនេះ តាមការគ្រោងទុកនឹងធ្វើការបើកសម្ពោធសាកល្បងនៅក្នុងត្រីមាសទី ៤ ឆ្នាំ ២០២៣។ បច្ចុប្បន្ន ក្រុមហ៊ុន កំពុងរៀបចំបំពាក់សម្ភារៈបរិក្ខារក្នុងបន្ទប់ទៅតាមជាន់មួយចំនួន និងបញ្ចប់ការសាងសង់កន្លែងលំហែក្នុងអគារដូចជា សួនច្បារ អាងហែលទឹក និងបន្ទប់ហាត់ប្រាណជាដើម ដើម្បីផ្តល់ឱ្យអតិថិជនរបស់យើងទទួលបាននូវបទពិសោធន៍ដ៏ល្អបំផុត។

សម្រាប់ឆ្នាំ ២០២៣ ក្រុមហ៊ុនបាននឹងកំពុងបន្តធ្វើការ យ៉ាងសកម្ម ដើម្បីចាំយកឱកាសអាជីវកម្មនិងបន្តពង្រឹងស្ថានភាពហិរញ្ញវត្ថុឲ្យកាន់តែមានភាពរឹងមាំឡើង។ យើងបន្តផ្តល់កន្លែងប្រកបដោយគុណភាព និងផ្តោតលើឧត្តមភាពប្រតិបត្តិការដែលគាំទ្រដល់តម្រូវការអចលនទ្រព្យរបស់អតិថិជនរបស់យើង។ យើងជឿជាក់ថាទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយនឹងអតិថិជន យុទ្ធសាស្រ្តច្បាស់លាស់ និងផែនការអនុវត្តន៍ជាក់លាក់នឹងជួយយើងឱ្យទទួលបានភាពរីកចម្រើនប្រកបដោយនិរន្តរភាពនាពេលអនាគតខាងមុខ។

ជាចុងបញ្ចប់ ក្នុងនាមក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងក្រុមការងារ ក្រុមហ៊ុន ហ្គោលដេន ទ្រី ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីថ្លែងអំណរគុណដល់ អតិថិជន មិត្តភក្តិ ដៃគូរ និងវិនិយោគិនដែលតែងតែគាំទ្រនិងផ្តល់ទំនុកចិត្តដល់ក្រុមហ៊ុន និងសូមជូនពរអ្នកឱ្យជួបតែសំណាងល្អគ្រប់វេលា។

ហ្គោលដេន ទ្រី
GOLDEN TREE
Co., Ltd.

លោក ហុង អ៊ុយ
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ: ១៤ សីហា ២០២៣

# មាតិការ


| | |
|---|---|
| ព័ត៌មានហិរញ្ញវត្ថុសង្ខេប | I |
| ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប | II |
| សមាសភាពក្រុមប្រឹក្សាភិបាល | III |
| សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល | V |
| ផ្នែកទី១ ព័ត៌មានទូទៅរបស់ បុគ្គលចុះបញ្ជីលក់មូលបត្រ | ១ |
| ផ្នែកទី ២ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច | ៦ |
| ផ្នែកទី៣ របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដោយសវនកររឯករាជ្យ | ៨ |
| ផ្នែកទី៤ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង | ១០ |
| ហត្ថលេខារបស់អភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ | ១៧ |
| ឧបសម្ព័ន្ធ | ១៨ |

# ផ្នែកទី១

# ព័ត៌មានទូទៅរបស់
# បុគ្គលចុះបញ្ជីលក់មូលបត្រ

## ក. អត្តសញ្ញាណរបស់ ក្រុមហ៊ុន ហ្គោលដេន ទ្រី

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ហ្គោលដេន ទ្រី |
| ជាអក្សរឡាតាំង | GOLDEN TREE |
| លេខកូដស្តង់ដារ | KH ២០០០២០១CC៧ |
| ទីស្នាក់ការ | ប្លុក A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ២២៤ ៧០១ |
| គេហទំព័រ | www.goldentree.com.kh |
| អ៊ីម៉ែល | enquiry@goldentree.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០១២៣៧៣ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារ ផ្តល់ព័ត៌មាន លេខ | ២៣១/២២ ន.ម.ក/ស.ស.រ ១២ តុលា ២០២២ |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក ហុង អ៊ុយ |

## ខ. លក្ខណៈនៃធុរៈកិច្ច

### ១. ការពិពណ៌នាសង្ខេបនៃអាជីវកម្ម

ក្រុមហ៊ុន ហ្គោលដេន ទ្រី គឺជាក្រុមហ៊ុនអចលនទ្រព្យឈានមុខគេមួយក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន ផ្តល់សេវាកម្មក្នុងការជួលការិយាល័យពាណិជ្ជកម្ម ការជួលលំនៅដ្ឋាន និងការគ្រប់គ្រងអចលនទ្រព្យ។

គោលបំណងចម្បងរបស់ក្រុមហ៊ុនគឺដើម្បីធានាផ្តល់នូវគុណភាពល្អបំផុត និងស្តង់ដារសេវាកម្ម សម្រាប់អ្នកជួលក្នុងអគារ វីត្រាស់។ បច្ចុប្បន្ន ក្រុមហ៊ុន ហ្គោលដេន ទ្រី មានអគារចំនួនពីរនៅចំកណ្តាលទីក្រុងភ្នំពេញ ដែលជាតំបន់មានសក្តានុពល។

- វីត្រាស់ ថៅវើ គឺជាអគារការិយាល័យពាណិជ្ជកម្មកម្ពស់ ១២ ជាន់ ដែលទទួលបានវិញ្ញាបនបត្រ EDGE (Excellence in Design for Greater Efficiencies) នៅថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០២២ ដោយ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសមាជិកនៃក្រុមធនាគារពិភពលោក។ បច្ចុប្បន្ននេះ វីត្រាស់ គឺជាអគារបៃតងទីពីរដែលបានទទួលវិញ្ញាបនបត្រ EDGE ដែលត្រូវបានបញ្ជាក់ដោយ IFC នៅក្នុងប្រទេសកម្ពុជា។
- អមរ៉ា រេស៊ីដេន (Amara Residence) ជាអគារលំនៅដ្ឋានកម្ពស់ ២៥ ជាន់ ដែល ក្រុមហ៊ុន ហ្គោលដេនទ្រី បានទិញក្នុងខែធ្នូ ឆ្នាំ ២០២២។ អគារនេះមានបំណងបើកដំណើរការជា អាផាតមិនសេវាកម្ម។

## ខ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាស របស់បុគ្គលចុះបញ្ជីលក់មូលបត្រ

១. ក្រុមហ៊ុន កំពុងបន្តកែលម្អគុណភាពនៃសហគមន៍ការិយាល័យរបស់យើង។ អាទិភាពមួយក្នុងចំណោមអាទិភាពជាច្រើនរបស់យើងគឺផ្តល់នូវបរិយាកាស ដែលផ្តល់នូវសុខុមាលភាពនិងផាសុកភាពជូនអតិថិជនដើម្បីគាំទ្រភាពជោគជ័យនៃអាជីវកម្មរបស់ពួកគេ។ យើងនឹងបន្តបង្កើតកន្លែងបរិយាកាសរីករាយសម្រាប់អតិថិជនដែលអាចឲ្យពួកគេ មានឱកាសសម្រាក ជជែក ពិភាក្សាការងារ និងកិច្ចសហប្រតិបត្តិការ អាជីវកម្មទៅតាមតម្រូវការរបស់ខ្លួន។

ហេតុនេះ ពួកយើងសម្រេចចិត្តដំណើរការហាងកាហ្វេនៅកន្លែងទទួលភ្ញៀវរបស់យើង។ យើងបានទិញសិទ្ធិដំណើរការហាងកាហ្វេអន្តរជាតិលំដាប់ថ្នាក់មួយគឺ - Gloria Jean's ដែលហាងកាហ្វេនេះនឹងដំណើរការនៅ ខែសីហា ឆ្នាំ២០២៣។







២. ការសាងសង់ អមរ៉ា រេស៊ីដេន បានដំណើរការមកដល់ដំណាក់កាលចុងក្រោយហើយ។ បច្ចុប្បន្ន ជាន់ទី ២២ ដែលមានអាងហែលទឹក និងកន្លែងហាត់ប្រាណស្ថិតក្នុងដំណាក់ចុងបញ្ចប់ហើយ។ លើសពីនេះ ក្រុមហ៊ុន កំពុងរៀបចំបញ្ចប់ទៅតាមបន្ទប់នៃជាន់មួយចំនួន ដែលអាចនឹងបើកដំណើរនៅត្រីមាសទី៤ ឆ្នាំ២០២៣។



រូបគម្រូ



រូបបច្ចុប្បន្ន





រូបគម្រូ

រូបបច្ចុប្បន្ន











រូបគម្រូ

រូបបច្ចុប្បន្ន

៣. នៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០២៣ ក្រុមប្រឹក្សាភិបាល និងភាគទុនិក បានធ្វើសន្និបាតភាគហ៊ុនិកវិសាមញ្ញ មួយដើម្បី សម្រេចលើ

- ការផ្លាស់ប្តូររចនាសម្ព័ន្ធម្ចាស់ភាគហ៊ុន
- ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល
- ការតម្កល់លក្ខន្តិកៈថ្មី របស់ ក្រុមហ៊ុន ហ្គោលដេន ទ្រី

កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ លក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុនត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម ព័ត៌មានលម្អិតមានដូចខាងក្រោម៖

## ១. ការផ្លាស់ប្តូររចនាសម្ព័ន្ធភាគហ៊ុនិក

| រចនាសម្ព័ន្ធភាគហ៊ុនិក | | | | | |
|---|---|---|---|---|---|
| មុនការកែប្រែ (គិតត្រឹមថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣) | | | ក្រោយការកែប្រែ (ចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ តទៅ) | | |
| ឈ្មោះភាគហ៊ុនិក | កាន់កាប់ភាគហ៊ុន | ភាគរយនៃកម្មសិទ្ធិ | ឈ្មោះភាគហ៊ុនិក | កាន់កាប់ភាគហ៊ុន | ភាគរយនៃកម្មសិទ្ធិ |
| លោក ហុង អ៊ុយ | ៥០០.០០០ | ៥០% | លោក ហុង អ៊ុយ | ៧៥០.០០០ | ៧៥% |
| លោក គុយ វ៉ាត | ៥០០.០០០ | ៥០% | លោក សុខ ពិសិដ្ឋ | ២៥០.០០០ | ២៥% |
| **សរុប** | **១.០០០.០០០** | **១០០%** | **សរុប** | **១.០០០.០០០** | **១០០%** |

## ២.ការផ្លាស់ប្តូររចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល

| រចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល | | | |
|---|---|---|---|
| មុនការកែប្រែ (គិតត្រឹមថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣) | | ក្រោយការកែប្រែ (ចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ តទៅ) | |
| សមាជិកក្រុមប្រឹក្សាភិបាល | តំណែង | សមាជិកក្រុមប្រឹក្សាភិបាល | តំណែង |
| លោក គុយ វ៉ាត | ប្រធានក្រុមប្រឹក្សាភិបាល | លោក ហុង អ៊ុយ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក ហុង អ៊ុយ | អភិបាលប្រតិបត្តិ | លោក សុខ ពិសិដ្ឋ | អភិបាលមិនប្រតិបត្តិ |
| លោក អៀង សៃ | អភិបាលមិនប្រតិបត្តិ | លោក អៀង សៃ | អភិបាលមិនប្រតិបត្តិ |
| លោក លី លាង | អភិបាលឯករាជ្យ | លោក លី លាង | អភិបាលឯករាជ្យ |
| លោក គឹង កបកល្យាន | អភិបាលឯករាជ្យ | លោក គឹង កបកល្យាន | អភិបាលឯករាជ្យ |

គិតត្រឹមថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២៣ លោក គុយ វ៉ាត បានលក់ភាគហ៊ុនទាំងអស់របស់គាត់ និងបានលាលែងពីប្រធានក្រុមប្រឹក្សាភិបាល។

ក្រុមប្រឹក្សាភិបាលសូមសំដែងការអំណរគុណជូនចំពោះ លោក គុយ វ៉ាត សម្រាប់ការលះបង់និងខិតខំនាពេលកន្លងមកចំពោះក្រុមហ៊ុន និងសូមសំដែងការអបអរសាទរជូនចំពោះ លោក ហុង អ៊ុយ និង លោក សុខ ពិសិដ្ឋ សម្រាប់ការជ្រើសតាំងថ្មី និងសង្ឃឹមយ៉ាងមុតមាំថាលោកនឹងបន្តដឹងនាំ ក្រុមហ៊ុនឲ្យបោះជំហានឈានទៅមុខ និងអភិវឌ្ឍប្រកបដោយនិរន្តភាព។

# ផ្នែកទី ២

# ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

ធាតុដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានវាស់វែងដោយប្រើរូបិយប័ណ្ណផ្អែកលើសេដ្ឋកិច្ចចម្បងដែលអង្គភាពដំណើរការ។ រូបិយប័ណ្ណជាតិរបស់កម្ពុជាគឺ ប្រាក់រៀលខ្មែរ (KHR)។ ទោះជាយ៉ាងណាក៏ដោយ ដោយសារ ក្រុមហ៊ុន ហ្គោលដេន ទ្រី ធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន និងរក្សាកំណត់ត្រាគណនេយ្យរបស់ខ្លួនជាចម្បងជាដុល្លារ ក្រុមប្រឹក្សាភិបាលបានកំណត់ប្រាក់ដុល្លារជារូបិយប័ណ្ណរបស់ក្រុមហ៊ុនសម្រាប់គោលបំណងវាស់វែង និងការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីខ្លឹមសារសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ការប្តូរប្រាក់ពីដុល្លារអាមេរិកទៅប្រាក់រៀល ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដើម្បីអនុលោមតាមច្បាប់ស្តី ពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការរបស់ធានាគារជាតិនៃ កម្ពុជា។

## ក. ប្រតិបត្តិការអាជីវកម្ម

ប្រភពចំណូលចម្បងរបស់ ក្រុមហ៊ុន គឺបានមកពីការជួលការិយាល័យ និងការប្រើប្រាស់សេវាផ្សេងៗក្នុង អគារ វីត្រាស់។

## ខ. រចនាសម្ព័ន្ធចំណូល

| | ត្រីមាសទី២ ២០២៣ | | | ត្រីមាសទី២ ២០២២ | | | ត្រីមាសទី២ ២០២១ | | |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លា | រៀល'000 | % | ដុល្លា | រៀល'000 | % | ដុល្លា | រៀល'000 | % |
| ចំណូលពីការជួល | ៤៥៧.៧២២ | ១.៨៧២.៩៩៨ | ៧១,៥០ | ៥៤៣.៨២០ | ២.២០៧.៣៦៥ | ៧០,៨៨ | ៦១១.៧៤៨ | ២.៤៨៨.៥៩១ | ៧៤,១៦ |
| ចំណូលពីការបង់ថ្លៃសេវា | ១០៦.៣៦៨ | ៤៣៥.២៥៨ | ១៦,៦២ | ១៤៤.៦៤៦ | ៥៨៧.១១៨ | ១៨,៨៥ | ១៤៣.៣២១ | ៥៨៣.០៣០ | ១៧,៣៧ |
| ចំណូលទឹកភ្លើង | ៦០.៤៤៨ | ២៤៧.៣៥៣ | ៩,៤៤ | ៦៧.៧៥១ | ២៧៥.០០១ | ៨,៨៣ | ៦២.១៥៣ | ២៥២.៨៣៨ | ៧,៥៣ |
| ចំណេត | ១២.៩៤៥ | ៥២.៩៧១ | ២,០២ | ១០.៧៣៥ | ៤៣.៥៧៤ | ១,៤ | ៧.៣៧១ | ២៩.៩៨៥ | ០,៨៩ |
| ចំណូលផ្សេងៗ | ២.៧០៣ | ១១.០៦១ | ០,៤២ | ២៩០ | ១.១៧៧ | ០,០៤ | ៣១១ | ១.២៦៥ | ០,០៤ |
| សរុប | ៦៤០.១៨៦ | ២.៦១៩.៦៤១ | ១០០% | ៧៦៧.២៤២ | ៣.១១៤.២៣៥ | ១០០% | ៨២៤.៩០៤ | ៣.៣៥៥.៧០៩ | ១០០% |

# ផ្នែកទី ៣

# របាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញ
# ដោយសវនករឯករាជ្យ

សូមយោងលើឧបសម្ព័ន្ធ សម្រាប់ព័ត៌មានហិរញ្ញវត្ថុក្នុងគ្រាដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។

# ផ្នែកទី៤

# ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងវិភាគខាងក្រោមនេះផ្តោតលើលទ្ធផលប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៣ ដែលត្រូវបានត្រួតពិនិត្យរួចរាល់ដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារបាយការណ៍ ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (CIFRS) ។ ក្រុមហ៊ុនធ្វើការពិភាក្សា និងវិភាគទៅលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុនិងកត្តាសំខាន់ៗ ដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុន ហ្គោលដេន ទ្រី តែប៉ុណ្ណោះ។

សូមបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២២ មិនត្រូវបានពិនិត្យ និងរងសវនកម្មទេ។

## ក. ទិដ្ឋភាពទូទៅ

### ១. ការវិភាគលើចំណូល

| | ត្រីមាសទី២ ២០២៣ | | ត្រីមាសទី២ ២០២២ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|
| | ដុល្លា | រៀល'000 | ដុល្លា | រៀល'000 | រៀល'000 | % |
| ចំណូលគោល | ៦៣៧.៤៨៣ | ២.៦០៨.៥៨០ | ៧៦៦.៩៥២ | ៣.១១៣.០៥៨ | (៥០៤.៤៧៨) | (១៦,២១) |
| ថ្លៃដើមសេវាកម្ម | (២១៧.៦៩៤) | (៨៩០.៨០៤) | (២០៧.០១៨) | (២០៧.២៨៦) | ៥០.៥១៨ | ៦,០១ |
| ចំណេញដុល | ៤១៩.៧៨៩ | ១.៧១៧.៧៧៦ | ៥៥៩.៩៣៤ | ២.២៧២.៧៧២ | (៥៥៤.៩៩៦) | (២៤,៤២) |
| ចំណូលផ្សេងៗ | ២.៧០៣ | ១១.០៦១ | ២៩០ | ១.១៧៧ | ៩.៨៨៤ | ៨៣៩,៧៦ |
| ចំណាយប្រតិបត្តិការ និងចំណាយរដ្ឋបាល | (១២៧.៥៤៧) | (៥២១.៩២២) | (១១៦.០០៦) | (៤៧០.៨៦៨) | ៥១.០៥៤ | ១០,៨៤ |
| ចំណេញប្រតិបត្តិការសុទ្ធ | ២៩៤.៩៤៥ | ១.២០៦.៩១៥ | ៤៤៤.២១៨ | ១.៨០៣.០៨១ | (៥៩៦.១៦៦) | (៣៣,០៦) |
| ចំណាយហិរញ្ញវត្ថុ | (៤២៤.១០៣) | (១.៧៣៥.៤២៩) | (៣៥០.៣៦៥) | (១.៤២២.១៣២) | ៣១៣.២៩៧ | ២២,០៣ |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | (១២៩.១៥៨) | (៥២៨.៥១៤) | ៩៣.៨៥៣ | ៣៨០.៩៤៩ | (៩០៩.៤៦៣) | (២៣៨,៧៤) |
| ចំណាយពន្ធលើប្រាក់ចំណូល | (៥.៨៩៤) | (២៤.១១៨) | (២.៦២១) | (១០.៦៣៩) | ១៣.៤៧៩ | ១២៦,៦៩ |
| ចំណេញសុទ្ធ | (១៣៥.០៥២) | (៥៥២.៦៣២) | ៩១.២៣២ | ៣៧០.៣១០ | (៩២២.៩៤២) | (២៤៩,២៣) |

### ២. កាលវិភាគចំណូលតាមផ្នែក

| | ត្រីមាសទី២ ២០២៣ | | ត្រីមាសទី២ ២០២២ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|
| | ដុល្លា | រៀល'000 | ដុល្លា | ដុល្លា | រៀល'000 | % |
| ចំណូលពីការជួល | ៤៥៧.៧២២ | ១.៨៧២.៩៩៨ | ៥៤៣.៨២០ | ២.២០៧.៣៦៥ | (៣៣៤.៣៦៧) | (១៥,១៥) |
| ចំណូលពីការបង់ថ្លៃសេវា | ១០៦.៣៦៨ | ៤៣៥.២៥៨ | ១៤៤.៦៤៦ | ៥៨៧.១១៨ | (១៥១.៨៦០) | (២៥,៨៧) |
| ចំណូលទឹកភ្លើង | ៦០.៤៤៨ | ២៤៧.៣៥៣ | ៦៧.៧៥១ | ២៧៥.០០១ | (២៧.៦៤៨) | (១០,០៥) |
| ចំណត | ១២.៩៤៥ | ៥២.៩៧១ | ១០.៧៣៥ | ៤៣.៥៧៤ | ៩.៣៩៨ | ២១,៥៧ |
| ចំណូលផ្សេងៗ | ២.៧០៣ | ១១.០៦១ | ២៩០ | ១.១៧៧ | ៩.៨៨៤ | ៨៣៩,៦៥ |
| **សរុប** | **៦៤០.១៨៦** | **២.៦១៩.៦៤១** | **៧៦៧.២៤២** | **៣.១១៤.២៣៥** | **(៤៩៤.៥៩៤)** | **(១៥,៨៨)** |

ប្រាក់ចំណូលពីការជួល និងការបង់ថ្លៃសេវាបានថយចុះ ដោយសារការថយចុះនៃអត្រាជួលពីអត្រាជួលជាមធ្យមក្នុងឆ្នាំ ២០២២ គឺ ៨៣% ខណៈដែលអត្រាជួលបច្ចុប្បន្នមានត្រឹមអត្រា ៧៧% គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៣។ ក្នុងអំឡុងត្រីមាសនេះ ក្រុមការងារលក់របស់យើងបានសម្រេចបានលទ្ធផលល្អដោយ ទទួលបានអតិថិជនដែលជាក្រុមហ៊ុនដឹកជញ្ជូនមានឈ្មោះបោះសំឡេងចំនួនពីរ ដែលពួកគេនឹងចាប់ផ្តើមជួលនៅក្នុង ត្រីមាសទី៤ ឆ្នាំ២០២៣ ក្នុងទំហំសរុបចំនួន ១.៣៩២ ម៉ែត្រការ៉េ។

### ៣. ការវិភាគប្រាក់ចំណេញសរុប

| | ត្រីមាសទី២ ២០២៣ | | ត្រីមាសទី២ ២០២២ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|
| | ដុល្លា | រៀល'000 | ដុល្លា | រៀល'000 | រៀល'000 | % |
| ចំណេញដុល | ៤១៩.៧៨៩ | ១.៧១៧.៧៧៦ | ៥៥៩.៩៣៤ | ២.២៧២.៧៧២ | (៥៥៤.៩៩៦) | (២៤,៤២) |

ប្រាក់ចំណេញដុលត្រូវបានកាត់បន្ថយដោយសារតែការថយចុះនៃប្រាក់ចំណូលនិងការកើនឡើងបន្តិចបន្តួចនៃថ្លៃសេវា។

ថ្លៃសេវាបានកើនឡើងចំនួន ៥០.៥១៨.០០០ រៀល ឬ ១០.៦៧៦ ដុល្លារអាមេរិក ស្មើនឹង ៦,០១% បើប្រៀបធៀបទៅនឹង ត្រីមាសទី ២ ឆ្នាំ ២០២២ ដោយសារការកើនឡើងនៃថ្លៃដើមនៃការថែទាំគាំពារអគារ ខណៈដែលការចំណាយផ្សេងទៀតភាគច្រើនថេរ។

ក្រុមហ៊ុន យកចិត្តទុកដាក់លើការថែទាំបង្ការលើសម្ភារៈបរិក្ខា។ ការថែទាំបង្ការពន្យារពេលអាយុនៃការប្រើប្រាស់ឧបករណ៍ កាត់បន្ថយការឆាប់ខូចខាត កាត់បន្ថយការចំណាយពេលជួសជុលធំៗដែលកើតឡើងដោយថាហេតុ ដែលនាំឲ្យមានការចំណាយខ្ពស់ រអាក់រអួលប្រតិបត្តិការនិងសេវាកម្មដែល នាំឲ្យអតិថិជនមានការមិនពេញចិត្ត។

### ៤. ចំណេញ/(ខាត)មុនបង់ពន្ធ

| | ត្រីមាសទី២ ២០២៣ | | ត្រីមាសទី២ ២០២២ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|
| | ដុល្លា | រៀល'000 | ដុល្លា | ដុល្លា | រៀល'000 | % |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | (១២៩.១៥៨) | (៥២៨.៥១៤) | ៩៣.៨៨៣ | ៣៨០.៩៤៩ | (៩០៩.៤៦៣) | (២៣៨,៧៤) |

*ការវិភាគលើការចំណាយរដ្ឋបាល*

- ការចំណាយរដ្ឋបាលបានកើនឡើងចំនួន ៥១.០៥៤.០០០ រៀល ឬ ១១.៥៤១ ដុល្លារអាមេរិក ស្មើនឹង ១០,៨៤% បើប្រៀបធៀបទៅនឹងត្រីមាសទី ២ ឆ្នាំ ២០២២ ដោយសារការកើនឡើងនៃប្រាក់បៀវត្សរ៍ និងចំនួនបុគ្គលិក ខណៈដែលការចំណាយផ្សេងទៀតភាគច្រើនថេរ។

*ការវិភាគលើការចំណាយហិរញ្ញវត្ថុ*

- ការចំណាយហិរញ្ញវត្ថុបានកើនឡើងចំនួន ៣១៣.២៩៧.០០០ រៀល ឬ ៧៣.៧៣៨ ដុល្លារអាមេរិក ស្មើនឹង ២២,០៣% បើធៀបនឹងត្រីមាសទី ២ ឆ្នាំ ២០២២ ដោយសារការចំណាយការប្រាក់ពីការបោះផ្សាយសញ្ញាបណ្ណបំណុលបៃតង និងកម្ចីធនាគារបន្ថែមដើម្បីទិញ អគារ អមរ៉ា រេស៊ីដេន សម្រាប់ពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន។

### ៥. ចំណេញ/(ខាត)ក្រោយបង់ពន្ធ

| | ត្រីមាសទី២ ២០២៣ | | ត្រីមាសទី២ ២០២២ | | បម្រែបម្រួល | |
|---|---|---|---|---|---|---|
| | ដុល្លា | រៀល'០០០ | ដុល្លា | ដុល្លា | រៀល'០០០ | % |
| ចំណេញសុទ្ធ | (១៣៥.០៥២) | (៥៥២.៦៣២) | ៩១.២៣២ | ៣៧០.៣១០ | (៩២២.៩៤២) | (២៤៩,២៣) |

មិនមានការផ្លាស់ប្តូរណាមួយគួរឱ្យកត់សម្គាល់ឡើយទៅលើពន្ធលើប្រាក់ចំណូលដែលបានបង់សម្រាប់ត្រីមាសនេះទេ។

យោងតាមអនុក្រឹត្យលេខ ៤២ អនក្រ/បក ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២២ ស្តីពីការលើកទឹកចិត្តពន្ធក្នុងវិស័យមូលបត្រ ក្រុមហ៊ុន ហ្គោលដេន ទ្រី រំពឹងថានឹងទទួលបានការលើកទឹកចិត្តពន្ធពីការបោះផ្សាយមូលបត្របំណុលបៃតងនៅឆ្នាំសារពើពន្ធបន្ទាប់នៃឆ្នាំ ២០២៤ ។

### ៦. ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៣ កត្តាសំខាន់ដែលធ្វើឱ្យប្រាក់ចំណេញរបស់ ក្រុមហ៊ុន ហ្គោលដេន ទ្រី ធ្លាក់ចុះគឺៈ

- ការថយចុះនៃប្រាក់ចំណូលដោយសារតែការថយចុះនៃអត្រាអ្នកជួល។
- ការចំណាយបន្ថែម ទាក់ទងនឹងការប្រាក់សម្រាប់កម្ចីធនាគារដើម្បីទិញអគារ អមរ៉ា រេស៊ីដេន និងសញ្ញាបណ្ណបំណុលបៃតង។ ក្រុមហ៊ុន រំពឹងថា អមរ៉ា រេស៊ីដេន នឹងទទួលបានប្រាក់ចំណូលនៅក្នុង ត្រីមាសទី៤ ។

## ខ. កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១. ការវិភាគពីលក្ខខណ្ឌនៃតម្រូវការនិងការផ្គត់ផ្គង់

សេដ្ឋកិច្ចកម្ពុជាត្រូវបានគេរំពឹងថានឹងមានកំណើនវិជ្ជមានក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ យោងតាមធនាគារជាតិនៃកម្ពុជា (NBC) សេដ្ឋកិច្ចកម្ពុជាត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងអត្រា ៥,៥% ក្នុងឆ្នាំ ២០២៣ ពោលគឺខ្ពស់ជាងអត្រាកំណើនជាមធ្យមចំនួន ០,៨% បើធៀបនឹង សមាជិកនៃសមាគមអាស៊ីអាគ្នេយ៍(អាស៊ាន)។ លើសពីនេះ កំណើនផលិតផលក្នុងស្រុកសរុប របស់កម្ពុជានឹងបន្តកើនឡើងដល់ ៥,៩ ភាគរយនៅឆ្នាំ ២០២៤ នេះបើយោងតាមរបាយការណ៍ព្យាករណ៍សេដ្ឋកិច្ចរបស់ OECD សម្រាប់អាស៊ីអាគ្នេយ៍ ចិន និងឥណ្ឌា ។

លើសពីនេះ អតិផរណាជាមធ្យមរបស់កម្ពុជាត្រូវបានគេរំពឹងថានឹងមានចំនួន ២% សម្រាប់ឆ្នាំ ២០២៣។ បំណុលសាធារណៈកម្ពុជា នៅតែត្រូវបានវាយតម្លៃថាស្ថិតក្នុងភាពអាចគ្រប់គ្រងបានដែលបំណុលនោះមានប្រមាណ ៣៦,៥% បើធៀប

នឹងផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ ២០២២។ ហានិភ័យនៃវិបត្តិបំណុលនៅតែមានកម្រិតទាប ដោយសារបំណុលកម្ពុជាស្ថិតក្នុងលក្ខខណ្ឌសម្បទាន និងអាចគ្រប់គ្រងបាន។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងធ្វើការយ៉ាងមមាញឹកក្នុងការជម្រុញ និងកែលម្អបរិយាកាសវិនិយោគនៅកម្ពុជា។ ការវិនិយោគផ្ទាល់ពីបរទេសនៅកម្ពុជាកើនដល់ ៤៥ ពាន់លានដុល្លារ គិតត្រឹមត្រីមាសទី ១ ឆ្នាំ ២០២៣ កើនឡើង ៩% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្នុងចំណោម ការវិនិយោគផ្ទាល់ពីបរទេស ប្រទេសចិនឈរលើគេក្នុងបញ្ជីដែលការវិនិយោគមានប្រមាណ ២០,៩៩ពាន់លានដុល្លារ។ វិស័យអចលនទ្រព្យ និងសំណង់បានទាក់ទាញប្រមាណ ៦ ពាន់លានដុល្លារ។

វិស័យទេសចរណ៍របស់កម្ពុជាកំពុងឈាន ត្រលប់មកវិញដ៏ធំមួយនៅឆ្នាំ២០២៣ ដោយក្រសួងទេសចរណ៍បានដាក់ចេញគោលដៅដើម្បីទទួលបាន ភ្ញៀវទេសចរចំនួន ៤.៥ លាននាក់ក្នុងឆ្នាំនេះ។ ក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ ២០២៣ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិជាង ២.១៦ លាននាក់ កើនឡើង ៥៣០ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ។

ដើម្បីទទួលបានភ្ញៀវទេសចរច្រើនតាមអ្វីដែលរំពឹងទុក រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេស ជាពិសេសព្រលានយន្តហោះ។ បច្ចុប្បន្នរដ្ឋាភិបាលកំពុងដំណើរការសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មីមួយទៀតគឺអាកាសយានដ្ឋានអន្តរជាតិតេជោ ដែលគ្រោងនឹងបើកដំណើរការនៅចុងឆ្នាំ២០២៤។

យោងតាមរបាយការណ៍ CBRE វិស័យការិយាល័យមានការអភិវឌ្ឍន៍ជាវិជ្ជមានគួរឲ្យកត់សម្គាល់ដែលគិតត្រឹមត្រីមាសទី២ ឆ្នាំ២០២៣ អាត្រាជួលការិយាល័យឯកកម្មសិទ្ធបានឈានដល់ ៧៣% បើទោះបីជាមានការផ្គត់ផ្គង់ច្រើនក៏ដោយ។

ទោះជាយ៉ាងណាក៏ដោយ ការផ្គត់ផ្គង់បន្ថែមចំនួន ២១៥.000 ម៉ែត្រការ៉េនៅចុងឆ្នាំ ២០២៣ នឹងនាំមកនូវការផ្គត់ផ្គង់សរុបជាង ១.១ លាន ម៉ែត្រការ៉េ ។ ការកើនឡើងនៃការផ្គត់ផ្គង់លើសនេះនឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអត្រាអ្នកជួល និងតម្លៃជួលការិយាល័យ។

សំណង់អគារការិយាល័យមានការផ្លាស់ប្តូរគួរជាទីកត់សម្គាល់ពីអគារឯកកម្មសិទ្ធមកជាអគារពហុកម្មសិទ្ធ ។ ការផ្គត់ផ្គង់នាពេលអនាគតសរុបចំនួន ៤០% ត្រូវបានរំពឹងថា ជាអគារពហុកម្មសិទ្ធិនៅចុងឆ្នាំ២០២៣នេះ ។ អគារពហុកម្មសិទ្ធិបានផ្តល់ឱ្យអ្នកអភិវឌ្ឍន៍គម្រោងនូវលំហូរសាច់ប្រាក់យ៉ាងរហ័ស ។ទោះជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងអចលនទ្រព្យគឺជាកង្វល់ចម្បងសម្រាប់អ្នកជួល ដោយសារអគារប្រភេទនេះមិនស្ថិតក្រោមកម្មសិទ្ធិរបស់អ្នកណាម្នាក់នោះទេ។ ដូច្នេះធ្វើឱ្យមានការលំបាកក្នុងការថែរក្សាអគារ និងបញ្ហាផ្សេងទៀតដែលត្រូវការការសម្របសម្រួលជាមួយអ្នកជួល។

អាជាតមិនសេវាកម្មបាន ងើបឡើងវិញជាវិជ្ជមាននៅឆ្នាំ ២០២៣។ ការត្រលប់មកវិញរបស់ អ្នកជួលដែលបានចាកចេញក្នុងអំឡុងពេលជំងឺរាតត្បាត ត្រូវបានរកឃើញថាជាកត្តាសំខាន់មួយដើម្បីជំរុញការស្ទុះងើបឡើងវិញនៃអត្រាជួល។

តម្រូវការ អាផាតមិនសេវាកម្មនៅក្នុងប្រទេសកម្ពុជា ភាគច្រើនជាជនបរទេស និងភ្ញៀវទេសចរអន្តរជាតិដែលមកស្នាក់នៅរយៈពេលវែង។ ប្រទេសកម្ពុជារំពឹងថានឹងមានភ្ញៀវទេសចរចំនួន ៤,៥ លាននាក់នឹងមកទស្សនានៅដំណាច់ឆ្នាំ ២០២៣។ ទីផ្សារត្រូវបានគេរំពឹងថានឹងបន្តមានតម្រូវការច្រើន ដោយហេតុថាចំនួនប្រតិបត្តិករសេវាកម្មអាផាមិនរបស់ពិភពលោកធំៗនៅក្នុងប្រទេសនៅមានកម្រិតនៅឡើយ ។

ជាលទ្ធផល អាផាមិនសេវាកម្មចំនួន ៤០៧ យូនីតត្រូវបានបញ្ចប់ការសាងសង់ ដែលនាំឱ្យការផ្គត់ផ្គង់សរុប មានចំនួន ៦.៦៩៥ ។ ៧៨០ យូនីតទៀតកំពុងបន្តការសាងសង់ ដែលនាំឱ្យការផ្គត់ផ្គង់នាពេលអនាគតកើនឡើងដល់ ៨.៤៧៥ នៅឆ្នាំ ២០២៤ ។

ខណ្ឌបឹងកេងកង ដូនពេញ និង ចំការមន នៅតែបន្តផ្គត់ផ្គង់អាផាតមិនសេវាកម្ម ក្នុងរាជធានីភ្នំពេញស្ទើរតែទាំងអស់ ដែលមានចំនួនប្រហែល ៧៥% នៃចំនួនសរុប ខណៈដែលខណ្ឌទាំងនោះជាខណ្ឌសម្បូរដោយតំបន់ពាណិជ្ជកម្ម ដែលបន្តទាក់ទាញអ្នកដែលមានទេពកោសល្យពីបរទេសមករស់នៅ។

គណៈគ្រប់គ្រងរបស់ ក្រុមហ៊ុន ហ្គោលដេន ទ្រី បានដឹងយ៉ាងច្បាស់អំពីកត្តាទាំងអស់នេះ និងហានិភ័យសេដ្ឋកិច្ចដែលអាចកើតឡើង និងបានរៀបចំយុទ្ធសាស្ត្រដើម្បីដោះស្រាយជាមួយនឹងកត្តាណាមួយដែលជះឥទ្ធិពលដល់អាជីវកម្មរបស់ក្រុមហ៊ុន។ បច្ចុប្បន្ននេះ ក្រុមហ៊ុនផ្តោតលើការអភិវឌ្ឍន៍យុទ្ធសាស្ត្រនៃការអនុវត្តប្រកបដោយនិរន្តរភាព និងស្តង់ដារ បរិស្ថាន សង្គមនិងអភិបាលកិច្ច (ESG) ដើម្បីធ្វើ ឲ្យក្រុមហ៊ុនមានភាពដាច់ដោយឡែកពីក្រុមហ៊ុនដ៏ទៃ។ ដូចគ្នានេះផងដែរ ក្រុមហ៊ុនរក្សាបាននូវភាពមានអនាម័យខ្ពស់ ដើម្បីធានាបាននូវសុខុមាលភាពដល់អ្នកជួល ការយកចិត្តទុកដាក់ពីតម្រូវការរបស់អតិថិជនដោយការផ្តល់សេវាកម្មប្រកបដោយវិជ្ជាជីវៈ និងថែរក្សាឲ្យបាននូវទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនស្របតាមស្តង់ដារខ្ពស់។

### ២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

មិនមាន

### ៣-ការវិភាគលើពន្ធ

ក្រុមហ៊ុន ហ្គោលដេន ទ្រី បានចុះបញ្ជីមូលបត្របំណុលរបស់ខ្លួននៅថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០២៣។ យោងតាមអនុក្រឹតលេខ ៤២ អនក្រ_បក ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២២ ស្តីពីការលើកទឹកចិត្តពន្ធក្នុងវិស័យមូលបត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា ដូច្នេះក្រុមហ៊ុន នឹងទទួលបានការលើកទឹកចិត្តពន្ធក្នុងវិស័យមូលបត្រ ។
បច្ចុប្បន្ននេះ មិនមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងបទប្បញ្ញត្តិពន្ធនៅក្នុងប្រទេសកម្ពុជា ដែលជះឥទ្ធិពលដល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទេ។

## ៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

មិនមាន

## គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

គិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៣ និងរយៈពេល ដូចគ្នាគិតត្រឹមថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២២ ប្រាក់ចំណូលត្រូវបានបង្ហាញនៅក្នុងផ្នែក A នៃផ្នែកនេះ ហើយក៏មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលត្រួតពិនិត្យឡើងវិញដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០២៣ ផងដែរ។

មិនមានការផ្លាស់ប្តូរជាសារវន្តក្នុងការលក់ និងប្រាក់ចំណូលសម្រាប់រយៈពេលនោះទេ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ក្រុមហ៊ុន មិនធ្លាប់ជួបប្រទះផលប៉ះពាល់ ណាមួយលើការប្រែប្រួលនៃអត្រាប្តូរប្រាក់រវាង ដុល្លា និង រៀល ទេ។ ជាងនេះទៅទៀត អត្រាប្តូរប្រាក់រវាង ដុល្លា និង រៀល មានស្ថិរភាពគួរអោយកត់សំគាល់។

ក្រុមហ៊ុន មិនធ្លាប់ជួបប្រទះផលប៉ះពាល់ជាសារវន្តលើអត្រាការប្រាក់ទេ ដោយសារកម្ចីធនាគារ និងសញ្ញា ប័ណ្ណរបស់ក្រុមហ៊ុន មានអត្រាការប្រាក់ថេរ ហើយមានឥណប្រតិទានរហូតដល់ឆ្នាំ ២០២៦ និង ២០២៧។

ក្រុមហ៊ុន មិនធ្លាប់ជួបប្រទះផលប៉ះពាល់ជាសារវន្ត ណាមួយលើតម្លៃទំនិញក្នុងអំឡុងពេលនេះទេ។

## ង-ផលប៉ះពាល់នៃអតិផរណា

ក្រុមហ៊ុន មិនធ្លាប់ជួបប្រទះផលប៉ះពាល់ ណាមួយលើអតិផរណាក្នុងអំឡុងពេលនេះទេ។

## ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នាពេលបច្ចុប្បន្ន ក្រុមហ៊ុន ហ្គោលដេន ទ្រី ជឿជាក់ថា មិនមានការប្រែប្រួលជាសារវន្តលើគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុណាមួយ ដែលធ្វើឱ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ នេះក្រោមការត្រួតពិនិត្យ ឬប៉ះពាល់ដល់លទ្ធផលប្រតិបត្តិការនាពេលអនាគតទេ។

# ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

បានអាន និងឯកភាព

លោក ហុង អ៊ុយ
ប្រធានក្រុមប្រឹក្សាភិបាល
កាលបរិច្ឆេទ: ១៤ សីហា ២០២៣

# ឧបសម្ព័ន្ធ

**ក្រុមហ៊ុនហ្គោលដេន ទ្រី**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

**របាយការណ៍ត្រួតពិនិត្យនិងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន**

សម្រាប់ការិយបរិច្ឆេទ ចាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ២០២៣ រហូតដល់
ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣

របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដែលភ្ជាប់មកជាមួយ គឺជាការប្រែសំរួលជាភាសាខ្មែរ ពីរបាយការណ៍ជាភាសាអង់គ្លេស។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ ឯកសារអង់គ្លេសត្រូវបានយកជាគោល។

**ក្រុមហ៊ុនហ្គោលដេន ទ្រី**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

**មាតិកា**


| | ទំព័រ |
|---|---|
| សេចក្តីថ្លែងការរបស់ក្រុមប្រឹក្សាភិបាល | ១ |
| របាយការណ៍នៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ២ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន | ៤ |
| របាយការណ៍ចំណូល ឬខាត និង លទ្ធផលពេញលេញសង្ខេបបណ្តោះអាសន្ន | ៦ |
| របាយការណ៍បម្រែបម្រួលមូលធនសង្ខេបបណ្តោះអាសន្ន | ៧ |
| របាយការណ៍លំហូរសាច់ប្រាក់សង្ខេបបណ្តោះអាសន្ន | ៨ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ននានា | ១០ |

**ក្រុមហ៊ុនហ្គោលដេន ទ្រី**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

## សេចក្តីថ្លែងការរបស់ក្រុមប្រឹក្សាភិបាល

យោងតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាលរួមជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបនៃក្រុមហ៊ុន ហ្គោលដេន ទ្រី នាការិយបរិច្ឆេទថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣ ហើយនិងការទាក់ទងនឹងរបាយការណ៍សង្ខេបចំណេញ ឬខាត និងលទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍ លំហូរសាច់ប្រាក់សម្រាប់ រយៈពេល ៦ខែ ព្រមទាំង កំណត់សម្គាល់សង្ខេបលើព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (ត្រូវបានគេស្គាល់ជារួមថា "ព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន") ត្រូវបានបង្ហាញដោយភាពត្រឹមត្រូវ តាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ នៃរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្ន។

តំណាងអោយក្រុមប្រឹក្សាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ហ្គោលដេន ទ្រី
GOLDEN TREE
Co., Ltd.
ទីស្នាក់ការរាជធានីភ្នំពេញ

**ហុង អ៊ុយ**
ប្រធានក្រុមប្រឹក្សាភិបាល

**Crowe (KH) Co., Ltd**
*Chartered Accountants*
Member Crowe International

Unit 4B, 4th floor, K1 Building,
#148, Mao Tse Toung Blvd (St.245)
Songkat ToulTompong 2
Khan Chomkarmon, Phnom Penh
Kingdom of Cambodia
Main +855 23 216 717
Fax +855 23 216 727
www.crowe.com.kh
info@crowe.com.kh

# របាយការណ៍នៃការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ជូនចំពោះភាគហ៊ុននិករបស់ក្រុមហ៊ុនហ្គោលដេន ទ្រី

យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវ របាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្នរបស់ក្រុមហ៊ុន ហ្គោលដេន ទ្រី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាព ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ននាកាលបរិច្ឆេទថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៣ ព្រមទាំងរបាយការណ៍ចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ សង្ខេបបណ្តោះអាសន្នសម្រាប់ត្រីមាស និងសេចក្តីសង្ខេបកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេប បណ្តោះអាសន្ន ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជាលេខ៣៤ “*ស្តីពីរបាយការណ៍ហិរញ្ញវត្ថុសង្ខេប*”។ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺ ធ្វើការសន្និដ្ឋានទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន ដោយផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ។

## វិសាលភាពនៃការត្រួតពិនិត្យ

យើងខ្ញុំបានធ្វើការត្រួតពិនិត្យ ដោយអនុលោមតាមរបាយការណ៍ទាក់ទងនឹងស្តង់ដារអន្តរជាតិនៃកម្ពុជា លើការត្រួតពិនិត្យលេខ ២៤១០ ស្តីពី “ការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុបណ្តោះអាសន្ន ដែលធ្វើឡើងដោយសវនករ ឯករាជ្យរបស់ក្រុមហ៊ុន”។ ការត្រួតពិនិត្យលើរបាយការណ៍សង្ខេបហិរញ្ញវត្ថុបណ្តោះអាសន្នរួមមាន ការចោទសួរបុគ្គលិកដែលពាក់ព័ន្ធផ្ទាល់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ និងគណនេយ្យ ព្រមទាំងការអនុវត្តនូវ ការវិភាគ និងនិតិវិធីក្នុងការត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យមានវិសាលភាពតិចជាងការធ្វើសវនកម្ម ដោយអនុលោម ទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហើយជាលទ្ធផល យើងខ្ញុំមិនអាចធ្វើការធានាថា បានដឹងនូវរាល់បញ្ហាសំខាន់ៗដែលអាចនឹងត្រូវកត់សម្គាល់ ក្នុងការធ្វើសវនកម្ម។ ដូច្នេះ យើងខ្ញុំមិនបញ្ចេញមតិយោបល់សវនកម្មនោះទេ។

**របាយការណ៍នៃការត្រួតពិនិត្យលើរបាយការណ៍**
**ហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្ន ជូនចំពោះភាគហ៊ុននិករបស់**
**ក្រុមហ៊ុនហ្គោលដេន ទ្រី**

## សេចក្ដីសន្និដ្ឋាន

យោងតាមការត្រួតពិនិត្យរបស់យើងខ្ញុំ មិនមានបញ្ហាណាមួយដែលធ្វើឲ្យយើងខ្ញុំ ជឿជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបបណ្ដោះអាសន្នរបស់ក្រុមហ៊ុនដែលបានភ្ជាប់មកជាមួយនេះ មិនបានបង្ហាញពីភាពត្រឹមត្រូវប្រកបដោយសារវន្តភាព និងសមស្របទៅតាមស្តង់ដារគណនេយ្យអន្តរជាតិកម្ពុជាលេខ ៣៤ ស្តីពី *"របាយការណ៍ហិរញ្ញវត្ថុបណ្ដោះអាសន្ន"* នោះទេ។

**Crowe (KH) Co., Ltd.**
ក្រុមហ៊ុនស្នងការគណនេយ្យករជំនាញ

**Onn Kien Hoe**
អភិបាល
ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២៣

**ក្រុមហ៊ុនហ្គោលដេន ទ្រី**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)

លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន**

ត្រឹមការិយបរិច្ឆេទថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

| | កំណត់សម្គាល់ | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ទ្រព្យសកម្ម | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និង បរិក្ខារ | ៨ | ៩,៥៤៨,៣៧៥ | ៣៩,៤៣៤,៧៨៩ | ៩,៥៥៣,៧០៥ | ៣៩,៣៣២,៦០៣ |
| ទ្រព្យវិនិយោគ | ៩ | ២២,៣៥៨,៦១០ | ៩២,៣៤១,០៥៩ | ២២,៥៧៦,៣២២ | ៩២,៩៤៦,៧១៨ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ៣១,៩០៦,៩៨៥ | ១៣១,៧៧៥,៨៤៨ | ៣២,១៣០,០២៧ | ១៣២,២៧៩,៣២១ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| មូលបត្របំណុលសាជីវកម្មដែលត្រូវទារ | ១៥ | - | - | ១,៤៧៤,៨៨៥ | ៦,០៧២,១០០ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ១០ | ១,៨០៤,៣៥៧ | ៧,៤៥១,៩៩៤ | ៤៣៦,៥៦៤ | ១,៧៩៧,៣៣៤ |
| ចំនួនទឹកប្រាក់ដែលត្រូវបង់ពីភាគីពាក់ព័ន្ធ | ២១ | ១០២,៥១២ | ៤២៣,៣៧៥ | ៦៧៤,៤៥៨ | ២,៧៧៦,៧៤៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១១ | ២៨,៨៦៥ | ១១៩,២១២ | ៤៤២,០៩០ | ១,៨២០,០៨៥ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ១,៩៣៥,៧៣៤ | ៧,៩៩៤,៥៨១ | ៣,០២៧,៩៩៧ | ១២,៤៦៦,២៦៣ |
| **ទ្រព្យសកម្មសរុប** | | ៣៣,៨៤២,៧១៩ | ១៣៩,៧៧០,៤២៩ | ៣៥,១៥៨,០២៤ | ១៤៤,៧៤៥,៥៨៤ |
| មូលធន និងបំណុល | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១២ | ៥,០០០,០០០ | ២០,០០០,០០០ | ៥,០០០,០០០ | ២០,០០០,០០០ |
| ចំណេញរក្សាទុក | | ៤៩១,០៦៩ | ១,៧៨៦,៣៩១ | ៧២៥,៤៨០ | ២,៩៥០,១៥១ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៦៨៥,២៧៣ | - | ៦២១,៦៥១ |
| **មូលធនសរុប** | | ៥,៤៩១,០៦៩ | ២២,៤៧១,៦១៤ | ៥,៧២៥,៤៨០ | ២៣,៥៧១,៨០២ |
| បំណុល | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី | ១៣ | ១៥,៦៩៣,២៩៣ | ៦៤,៨១៣,៣០០ | ១៥,៤៧០,៦៩០ | ៦៣,៦៩២,៨៣១ |
| បំណុលភតិសន្យា | ១៤ | ៥០,៧២៦ | ២០៩,៤៩៨ | ៦៦,៣៣១ | ២៧៣,០៨៥ |
| មូលបត្របំណុលសាជីវកម្មដែលត្រូវបង់ | ១៥ | ១,៤៦៨,១០៩ | ៦,០៦៣,២៩០ | ១,៤៧៤,៨៨៥ | ៦,០៧២,១០០ |
| ពន្ធពន្យារលើបំណុល | | ៤៩៧,៧០៧ | ២,០៥៥,៥៣០ | ៦០៤,២៩០ | ២,៤៨៧,៨៦២ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៦ | ៦៣៧,៧២១ | ២,៦៣៣,៧៨៨ | - | - |
| ចំនួនទឹកប្រាក់ដែលត្រូវបង់ទៅភាគីពាក់ព័ន្ធ | ២១ | ៥,១៩០,០០០ | ២១,២២៨,២០០ | - | - |
| | | ២៣,៤៨៧,៥៥៦ | ៩៧,០០៣,៦០៦ | ១៧,៦១៦,១៩៦ | ៧២,៥២៥,៨៧៨ |

**ក្រុមហ៊ុនហ្គោលដេន ទ្រី**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)

លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន (តពីទំព័រមុន)

ត្រឹមការិយបរិច្ឆេទថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

| | កំណត់សម្គាល់ | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣ | | បានធ្វើសវនកម្ម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៦ | ៩១៤,៦២៧ | ៣,៧៧៧,៤១០ | ១,២៧៩,៧៩០ | ៥,២៦៨,៨៩៥ |
| ប្រាក់កម្ចី | ១៣ | ៣,៩៦៨,៨៦៧ | ១៦,៣៩១,៤២១ | ៤,៨០៥,០៩៦ | ១៩,៧៨២,៥៨០ |
| បំណុលលើការជួល | ១៤ | ៣០,៦០០ | ១២៦,៣៧៨ | ២៩,៤០៤ | ១២១,០៥៦ |
| មូលបត្របំណុលសាជីវកម្មដែលត្រូវបង់ | ១៥ | - | - | ២,០៥៨ | ៨,៤៧៣ |
| ចំនួនទឹកប្រាក់ដែលត្រូវបង់ពីភាគីពាក់ព័ន្ធ | ២១ | - | - | ៥,៧០០,០០០ | ២៣,៤៦៦,៩០០ |
| **បំណុលរយៈពេលខ្លីសរុប** | | ៤,៩១៤,០៩៤ | ២០,២៩៥,២០៩ | ១១,៨១៦,៣៤៨ | ៤៨,៦៤៧,៩០៤ |
| **បំណុលសរុប** | | ២៨,៤០១,៦៥០ | ១១៧,២៩៨,៨១៥ | ២៩,៤៣២,៥៤៤ | ១២១,១៧៣,៧៨២ |
| **មូលធន និងបំណុលសរុប** | | ៣៣,៨៤២,៧១៩ | ១៣៩,៧៧០,៤២៩ | ៣៥,១៥៨,០២៤ | ១៤៤,៧៤៥,៥៨៤ |

**ក្រុមហ៊ុនហ្គោលដេន ទ្រី**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)

លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

## របាយការណ៍ចំណូល ឬខាត និង លទ្ធផលពេញលេញសង្ខេបបណ្តោះអាសន្ន

សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

| | កំណត់សម្គាល់ | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៣ ខែត្រឹម ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣ | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៣ ខែត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណូល | ១៧ | ៦៣៧,៤៨៣ | ២,៦០៨,៥៨០ | ៧៦៦,៩៥២ | ៣,១១៣,០៥៨ |
| ថ្លៃដើម | ១៨ | (២១៧,៦៩៤) | (៨៩០,៨០៤) | (២០៧,០១៨) | (៨៤០,២៨៦) |
| **ចំណេញដុល** | | ៤១៩,៧៨៩ | ១,៧១៧,៧៧៦ | ៥៥៩,៩៣៤ | ២,២៧២,៧៧២ |
| ចំណូលផ្សេងៗ | | ២,៧០៣ | ១១,០៦១ | ២៩០ | ១,១៧៧ |
| ចំណាយរដ្ឋបាល | | (១២៧,៥៤៧) | (៥២១,៩២២) | (១១៦,០០៦) | (៤៧០,៨៦៨) |
| ឱនភាពចំណាយ | | - | - | - | - |
| **ចំណេញប្រតិបត្តិការ** | | ២៩៤,៩៤៥ | ១,២០៦,៩១៥ | ៤៤៤,២១៨ | ១,៨០៣,០៨១ |
| ចំណាយហិរញ្ញប្បទាន | ១៩ | (៤២៤,១០៣) | (១,៧៣៥,៤២៩) | (៣៥០,៣៦៥) | (១,៤២២,១៣២) |
| **(ខាត)/ចំណេញមុនបង់ពន្ធ** | | (១២៩,១៥៨) | (៥២៨,៥១៤) | ៩៣,៨៥៣ | ៣៨០,៩៤៩ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២០ | (៥,៨៩៤) | (២៤,១១៨) | (២,៦២១) | (១០,៦៣៩) |
| **(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ** | | (១៣៥,០៥២) | (៥៥២,៦៣២) | ៩១,២៣២ | ៣៧០,៣១០ |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| **(ចំណាយ)/ចំណូលលម្អិតផ្សេងៗសរុប** | | (១៣៥,០៥២) | (៥៥២,៦៣២) | ៩១,២៣២ | ៣៧០,៣១០ |

**ក្រុមហ៊ុនហ្គោលដេន ទ្រី**

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)

លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

# របាយការណ៍ចំណូល ឬខាត និង លទ្ធផលពេញលេញសង្ខេបបណ្តោះអាសន្ន

សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

| | កំណត់សម្គាល់ | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២៣ | | បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម ៦ ខែត្រឹម ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០២២ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់៤) |
| ចំណូល | | ១,៣៧៧,៤៥០ | ៥,៦៣៦,៥២៥ | ១,៥២៦,៣១០ | ៦,១៩៥,២៩២ |
| ថ្លៃដើម | | (៤៣៩,៧៩៤) | (១,៧៩៩,៦៣៧) | (៤២៤,៧៩១) | (១,៧២៤,២២៧) |
| **ចំណេញដុល** | | ៩៣៧,៦៥៦ | ៣,៨៣៦,៨៨៨ | ១,១០១,៥១៩ | ៤,៤៧១,០៦៥ |
| ចំណូលផ្សេងៗ | | ៣,០៩៩ | ១២,៦៨១ | ៦៥៨ | ២,៦៧១ |
| ចំណាយរដ្ឋបាល | | (២៦៤,១០២) | (១,០៨០,៧០៥) | (២៥២,៦៨៨) | (១,០២៥,៦៦១) |
| ឱនភាពចំណាយ | | (២២០,៥៩៨) | (៩០២,៦៨៧) | - | - |
| **ចំណេញប្រតិបត្តិការ** | | ៤៥៦,០៥៥ | ១,៨៦៦,១៧៧ | ៨៤៩,៤៨៩ | ៣,៤៤៨,០៧៥ |
| ចំណាយហិរញ្ញប្បទាន | | (៨៣៤,០១៣) | (៣,៤១២,៧៨១) | (៦៥០,៥២៧) | (២,៦០៤,៤៨៩) |
| **(ខាត)/ចំណេញមុនបង់ពន្ធ** | | (៣៧៧,៩៥៨) | (១,៥៤៦,៦០៤) | ១៩៨,៩៦២ | ៨៤៣,៥៨៦ |
| ចំណាយពន្ធលើប្រាក់ចំណូល | | ៩៣,៥៤៧ | ៣៨២,៧៩៤ | (១៤,៣៩៧) | (៥៨,៤៣៧) |
| **(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ** | | (២៨៤,៤១១) | (១,១៦៣,៨១០) | ១៨៤,៥៦៥ | ៧៨៥,១៤៩ |
| ចំណូលលម្អិតផ្សេងៗ | | - | - | - | - |
| **(ចំណាយ)/ចំណូលលម្អិតផ្សេងៗសរុប** | | (២៨៤,៤១១) | (១,១៦៣,៨១០) | ១៨៤,៥៦៥ | ៧៤៩,១៤៩ |

# ក្រុមហ៊ុនហ្គោលដេន ទ្រី
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
លេខចុះបញ្ជីក្រុមហ៊ុន: ០០០១២៣៧៣

## របាយការណ៍បម្រែបម្រួលមូលធនសង្ខេបបណ្តោះអាសន្ន
សម្រាប់ការិយបរិច្ឆេទថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

| | កំណត់សម្គាល់ | ដើមទុន ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សម្គាល់៤) |
|---|---|---|---|---|---|
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ ២០២៣ (បានធ្វើសវនកម្ម) | | ៥,០០០,០០០ | ៧២៥,៤៨០ | ៥,៧២៥,៤៨០ | ២២,៩៥០,១៥១ |
| សរុបការចំណាយលម្អិត | | - | (២៨៤,៤១១) | (២៨៤,៤១១) | (១,១៦៣,៨១០) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | ៦៨៥,២៧៣ |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០២៣ (ដុល្លារអាមេរិក) (បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម) | | ៥,០០០,០០០ | ៤៤១,០៦៩ | ៥,៤៤១,០៦៩ | ២២,៤៧១,៦១៤ |
| | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ ២០២២ (បានធ្វើសវនកម្ម) | | ៥,០០០,០០០ | ៦៧០,០៥១ | ៥,៦៧០,០៥១ | ២២,៧២៧,១០៨ |
| សរុបការចំណេញលម្អិត | | - | ១៨៤,៥៦៥ | ១៨៤,៥៦៥ | ៧៤៩,១៤៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | ៣៥២,០៣០ |
| សមតុល្យគិតត្រឹមថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០២២ (ដុល្លារអាមេរិក) (បានត្រួតពិនិត្យតែមិនបានធ្វើសវនកម្ម) | | ៥,០០០,០០០ | ៨៥៤,៦១៦ | ៥,៨៥៤,៦១៦ | ២៣,៨២៨,២៨៧ |

## ក្រុមហ៊ុនហ្គោលដេន ទ្រី
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
លេខចុះបញ្ជីក្រុមហ៊ុនៈ ០០០១២៣៧៣

## របាយការណ៍លំហូរសាច់ប្រាក់សង្ខេបបណ្តោះអាសន្ន
